

USAID
ជំនួយពីប្រជាជនអាមេរិក

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែវិច្ឆិកា ឆ្នាំ២០២៣

WFP
World Food Programme

SAVING LIVES
CHANGING LIVES

## ប្រទេសកម្ពុជា

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


**ការិយាល័យទីផ្សារកសិកម្ម (AMO)**
នាយកដ្ឋានផែនការនឹងស្ថិតិ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**វិភាគ និងធ្វើផែនទីភាពងាយរងគ្រោះ (VAM)**
ផ្នែកស្រាវជ្រាវ វាយតម្លៃ និងតាមដាននៃកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org ,
ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org, ហួយ វណ្ណារ៉េត vannareth.huoy@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ អតិផរណាស្បៀងអាហារសកលនៅតែខ្ពស់** ដោយសារតែជម្លោះរវាងអ៊ីស្រាអែល និងប៉ាឡេស្ទីននាពេលថ្មីៗ ការវាយប្រហារជាបន្តបន្ទាប់របស់រុស្ស៊ីទៅលើហេដ្ឋារចនាសម្ព័ន្ធនាំចេញរបស់អ៊ុយក្រែន ការបិទការនាំចេញស្បៀងអាហាររបស់ប្រទេសជាអ្នកផលិតមួយចំនួន និងភាពមិនច្បាស់លាស់ទាក់ទងបាតុភូតអែលនីញ៉ូ មានឥទ្ធិពលលើផលិតកម្មកសិកម្មសកល។

**សន្ទស្សន៍តម្លៃម្ហូបអាហារពិភពលោករបស់ FAO ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ មានស្ថេរភាព។** ដោយសារតែការកើនឡើងតម្លៃស្ករ ប្រេងឆា និងផលិតផលទឹកដោះគោ បានទូទាត់ជាមួយនឹងការថយចុះតម្លៃធញ្ញជាតិ និងសាច់។ គួរកត់សម្គាល់ថា សន្ទស្សន៍នេះទាបជាងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ១០,៧%។ **សន្ទស្សន៍តម្លៃអង្ករសរុបរបស់ FAO នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣** ក៏មានស្ថេរភាពដែរ បើធៀបនឹងខែមុន ប៉ុន្តែវា**នៅតែខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ២១,២%។**

**ប្រទេសឥណ្ឌាទំនងជានៅតែបន្តបិទការនាំចេញអង្ករហូតដល់ការបោះឆ្នោតនៅក្នុងខែមេសា-ឧសភា ឆ្នាំ២០២៤ រួចរាល់។** ការបិទការនាំចេញនេះ បានកាត់បន្ថយនូវការផ្គត់ផ្គង់អង្ករសកលគួរឱ្យកត់សម្គាល់។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តម្លៃអង្ករ បានកើនឡើងខ្ពស់ជាថ្មីម្តងទៀតក្នុងរយៈពេល១៥ឆ្នាំ ដោយសារតម្រូវការ ដែលបានកើនឡើងមិនស្របគ្នានឹងការផ្គត់ផ្គង់។ តម្លៃអង្ករសកលត្រូវបានព្យាករថានឹងនឹងកើនឡើង ៦% ក្នុងឆ្នាំ២០២៤ បន្ទាប់ពីបានកើនឡើង ២៨% ក្នុងឆ្នាំ២០២៣។ ស្ថានភាពនេះ បានបង្កើននូវក្តីព្រួយបារម្ភអំពីសន្តិសុខស្បៀងជាសកល ដោយសារអង្ករជាអាហារចម្បងសម្រាប់មនុស្សជាង ៣ ពាន់លាននាក់។

**បាតុភូតអែលនីញ៉ូបច្ចុប្បន្ន** រំពឹងថានឹងមានកម្រិតខ្លាំងបំផុតកំឡុងខែវិច្ឆិកា ឆ្នាំ២០២៣ ដល់ខែមករា ឆ្នាំ២០២៤ ហើយនឹងចុះខ្សោយជាបន្តបន្ទាប់ ខណៈពេលដែលវានៅតែមានសកម្មភាពពីខែមីនា ដល់ខែឧសភា ឆ្នាំ២០២៤។ ផលិតកម្មរបស់ប្រទេសថៃ រំពឹងថានឹងថយចុះ ៦% ក្នុងឆ្នាំ២០២៣-២០២៤ ដោយសារតែបាតុភូតអាកាសធាតុ។ ទន្ទឹមនឹងនេះ ប្រទេសវៀតណាមបានណែនាំដល់កសិករមួយចំនួនឱ្យចាប់ផ្តើមដាំដំណាំជាថ្មីឱ្យបានឆាប់ ជាការប្រុងប្រយ័ត្ននឹងគ្រោះរាំងស្ងួតដែលអាចកើតមាន។

**ផលិតកម្មកសិកម្ម និងស្បៀងអាហារសកលត្រូវបានព្យាករថានឹងបន្តកើនឡើងក្នុងទសវត្សរ៍ក្រោយ។** ប៉ុន្តែមានការព្យាករថាវានឹងកើនឡើងយឺត ដោយសារតែការកើនឡើងយ៉ាងខ្លាំងនៃតម្លៃធាតុចូលកសិកម្ម ក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀង នៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា** កម្មវិធីស្បៀងអាហារពិភពលោក (WFP) និងការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) បាន សហការគ្នាតាមដានតម្លៃស្បៀងអាហារសំខាន់ៗ និងដំណើរការរបស់ផ្សារចំនួន៥៦។ ប្រធានផ្សារ និងអាជីវករ ចំនួនប្រហែល ១.០០០ នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍ ដោយវាយតម្លៃពីការផ្គត់ផ្គង់ និងតម្រូវការ។ តម្លៃប្រេងសាំង ប្រេងម៉ាស៊ូត និងប្រាក់ឈ្នួលពលកម្មក៏ត្រូវបានតាមដានផងដែរ។

# មាតិកា


**១. របកគំហើញសំខាន់ៗ** ៣

**២. លទ្ធផល**

ការដំណើរការរបស់ផ្សារ ៤

ការទៅផ្សារ៖ ទិន្នាការអតិថិជន ៥

ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រីកួន ៧

ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ៨

ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ នឹងទីប្រជុំជន ៩

ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ ១០

ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១១

ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១២

**៣. បរិបទ**

ពាណិជ្ជកម្ម ១៣

ការឆ្លើយតបផ្នែកនយោបាយ ១៤

**៤. វិធីសាស្រ្ត និងទីតាំងផ្សារ** ១៥

**៥. ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៦

**៦. ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៧

**៧. ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៨

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

២០២២ ៥.២%

២០២៣ ៥.៤% (ព្យាករណ៍)

*ធនាគារពិភពលោកបានព្យាករកំណើនសេដ្ឋកិច្ចកម្ពុជាថាថយពី ៥,៥% មក ៥,៤% ក្នុងឆ្នាំ ២០២៣។ តាំងពីដើមឆ្នាំមក **សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម* (CPI)** និង**សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា*(FPI)** មាននិន្នាការកើនឡើង។ **ក្នុងខែតុលា ឆ្នាំ២០២៣** សន្ទស្សន៍ទាំង២ បានកើនឡើងបង្គួរ ធៀបនឹងខែដូចគ្នាកាលពីឆ្នាំ២០២២ ហើយខ្ពស់ជាងឆ្នាំ២០២១គួរឱ្យកត់សម្គាល់។ គ្រួសារកម្ពុជាចំណាយស្ទើរតែពាក់កណ្តាល (៥២%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ។ គ្រួសារក្នុងក្រុមចំណាយទាបបំផុតបានចំណាយ រហូតដល់៥៨% (CSES ២០២១)។*

**អតិផរណា**

**ទិន្នន័យចុងក្រោយបំផុត មិនទាន់មាននៅឡើយ កំឡុងពេលរៀបចំរបាយការណ៍។*




*<u>តម្លៃប្រេងឥន្ធនៈនៅកម្ពុជា</u> ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ បានបន្តថយចុះបង្គួរ។ ការថយចុះតម្លៃឥន្ធនៈ ទំនងជាដោយសារ<u>ការលើកលែងការរិតបន្តឹងការនាំចេញប្រេងម៉ាស៊ូតភាគច្រើនរបស់ប្រទេសរុស្ស៊ី។</u>*

**ប្រេងឥន្ធនៈ**




# សង្ខេបរបកគំហើញសំខាន់ៗ

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ **កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) មានស្ថេរភាព** ធៀបនឹងខែមុន (MoM) ដល់តម្លៃ ២៨,៤ ដុល្លារ ក្នុងម្នាក់ ក្នុងមួយខែ។ ប៉ុន្តែ គួរកត់សម្គាល់ថា កញ្ចប់ស្បៀងអាហារតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន (YoY) ៣,៩%។ តម្លៃកញ្ចប់នៅតំបន់ទីប្រជុំជនបានកើនឡើងខ្ពស់នៅតំបន់ជនបទ។

តម្លៃស្បៀងអាហារនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដានភាគច្រើនមានស្ថេរភាពធៀបនឹងខែមុន ជាមួយនឹងការប្រែប្រួលតិចតួច (ទាបជាង ៥%) ក្នុងខែវិច្ឆិកា។ ប៉ុន្តែតម្លៃត្រកួនបានកើនឡើង ៨,៩% ធៀបនឹងខែមុន ស្របនឹងបម្រែបម្រួលតម្លៃតាមរដូវកាលរបស់វា។ គួរកត់សម្គាល់ថា **អង្ករមានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន ២៩,១%។** មួយវិញទៀត ត្រីផ្ទក់នៅតែមានតម្លៃខ្ពស់ជាងកាលពីឆ្នាំ២០២២ តាំងពីខែមិថុនា មកម្ល៉េះ ដោយមានកំណើន ៥,១% YoY ក្នុងខែវិច្ឆិកា។

**អំណាចទិញរបស់ក្រុមងាយរងគ្រោះមានការប្រែប្រួលជាវិជ្ជមាន** ដោយសារការថយចុះបន្តិចនៃតម្លៃស្បៀងអាហារ និងការកើនឡើងបង្គួរនៃប្រាក់ឈ្នួលពលកម្ម។ ចំនួនអតិថិជនមកផ្សារក្នុងខែវិច្ឆិកាក៏មានការកើនឡើងដែរ ទំនងជាដោយសារតែការកើនឡើងនូវតម្រូវការកំឡុងពេលបុណ្យភ្ជុំអុំទូក។ ប៉ុន្តែ ផ្សារមានដំណើរការមិនសូវល្អ ដោយសារតែតម្លៃទំនិញមិនមានស្ថេរភាព។

ផ្ទៃដីប្រមូលផលស្រូវរដូវវស្សាមានចំនួន **១ លានហិកតា** ខណៈដែលផ្ទៃដីដាំដុះស្រូវប្រាំងសម្រេចបានចំនួន **២៣% នៃផែនការថ្នាក់ជាតិ** ដោយសារតែធាតុអាកាសអំណោយផល និងមានទឹកស្រោចស្រពគ្រប់គ្រាន់។

# ការដំណើរការរបស់ផ្សារ

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ សន្ទស្សន៍ដំណើរការរបស់ផ្សារ* (MFI) បានថយចុះបន្តិចធៀបនឹងខែមុន។ នេះដោយសារតែការថយចុះនូវស្ថេរភាពតម្លៃទំនិញសំខាន់ៗ និងភាពអាចរកបានជាក់ស្តែងនៃទំនិញចាំបាច់ក្នុងបរិមាណគ្រប់គ្រាន់ ពិសេសនៅក្នុងសប្តាហ៍ទី១នៃខែ។ ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារត្រូវបានសម្ភាសន៍ស្តីពីស្ថានភាពនៃការផ្គត់ផ្គង់ស្បៀងអាហារ។ នៅក្នុងខែតុលា មានប្រធានផ្សារ និងអ្នកលក់ដែលបានសម្ភាសន៍ចំនួន ៣,៥% ដែលបានរាយការណ៍ថាមានការកើនឡើងតម្លៃផ្គត់ផ្គង់អង្ករ ត្រី និងបន្លែ។




** សន្ទស្សន៍ដំណើរការផ្សារ (MFI) វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ សមាសធាតុនីមួយៗនៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់ បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។ ចាប់ពីខែមេសា ឆ្នាំ២០២៣មក ការគណនា MFI និងសមាសធាតុសំខាន់ៗត្រូវបានកែសម្រួលដើម្បីបង្ហាញព័ត៌មានកាន់តែសុក្រិត។*

# **ការនៅផ្សារ៖** ទិន្នាការអតិថិជន

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ មានការកើនឡើងគួរឱ្យកត់សម្គាល់នូវចំនួនអតិថិជនទៅផ្សារបើធៀបនឹងខែមុន។ ការកើនឡើងនេះអាចដោយសារតែការប្រារព្ធពិធីបុណ្យប្រពៃណីដ៏ធំរបស់កម្ពុជា (បុណ្យអុំទូក) ជាលើកដំបូង បន្ទាប់ពីបានផ្អាកអស់រយៈពេល៣ឆ្នាំ ដោយសារការរាតត្បាតជំងឺកូវីដ-១៩។




**បម្រែបម្រួលនៃចំនួនអតិថិជន*មកផ្សារ**

** ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារចំនួន ៥៦ កន្លែង ដែលបានតាមដានតម្លៃនៅទូទាំងប្រទេស ក៏ត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សារនៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ ដោយប្រៀបធៀបទៅនឹងរយៈពេលពីរសប្តាហ៍មុន។ តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន[1] (BFB) បានមានស្ថេរភាព ដោយបានកើនបន្តិច ០,៣% ធៀបនឹងខែមុន (MoM) ដោយមានតម្លៃ ១១៦.៣០០ រៀល/ម្នាក់/ខែ (ប្រហែល ២៨,៤ ដុល្លារ)។ តម្លៃ BFB នៅផ្សារតំបន់ទីប្រជុំជនបានថយចុះ ១,៧% (២៩,៣ ដុល្លារ) ធៀបនឹងខែមុន ខណៈដែលតម្លៃ BFB នៅផ្សារតំបន់ជនបទបានកើនឡើង ២,៣% (២៧,៧ ដុល្លារ) ធៀបនឹងខែមុន។

ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY) តម្លៃ BFB បានកើនឡើងបង្គួរ ៣,៩%។ តម្លៃ BFB បានកើនឡើងខ្ពស់នៅផ្សារតំបន់ទីប្រជុំជន ជាងផ្សារនៅតំបន់ជនបទ។ គួរកត់សម្គាល់ថា BFB មានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំ២០២១ ចំនួន ៧,៩%។




*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។*

*[2] ផ្សារនៅទីប្រជុំជនសំដៅដល់ផ្សារដែលស្ថិតនៅទីរួមខេត្ត ហើយផ្សារដទៃទៀតចាត់ទុកថាជាផ្សារនៅជនបទ។*

## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្អក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី ៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តម្លៃលក់រាយអង្ករចម្រុះមានស្ថេរភាពធៀបនឹងខែមុន (MoM) ប៉ុន្តែបានកើនឡើងគួរឱ្យកត់សម្គាល់ ២៩,១% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY)។ តម្លៃលក់រាយស៊ុតទាបានកើនឡើង ២,៩% MoM តែថយចុះ ៥,៨% YoY។ តម្លៃលក់រាយត្រកួនបានកើនឡើង ៨,៩% MoM ប៉ុន្តែថយចុះ ៦,៨% YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖*

*- ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។*

*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តម្លៃលក់រាយត្រីផ្ទក់ បានថយចុះគួរឱ្យកត់សម្គាល់ ៦,៨% ធៀបនឹងខែមុន (MoM) ខណៈ តម្លៃសាច់ជ្រូក និងប្រេងឆាមានស្ថេរភាព MoM. ប៉ុន្តែ នៅពេលធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន (YoY) តម្លៃមាននិន្នាការខុសគ្នាគួរឱ្យកត់សម្គាល់។ តម្លៃលក់រាយត្រីផ្ទក់នៅតែខ្ពស់ គឺ ៥,១% YoY ខណៈតម្លៃលក់រាយប្រេងឆាមានតម្លៃទាបគួរឱ្យកត់សម្គាល់ គឺ ១៦,៧% ហើយសាច់ជ្រូកមានតម្លៃទាបគួរឱ្យកត់សម្គាល់ គឺ ១០,៧%។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




*សម្គាល់៖ តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ តម្លៃមធ្យមលក់រាយស្បៀងអាហារដែលបានតាមដានភាគច្រើន (ក្រាហ្វិកខាងក្រោមឆ្វេង) មានទិសដៅប្រែប្រួលដូចគ្នា ទាំងនៅផ្សារជនបទ និងផ្សារទីប្រជុំជន។ តម្លៃស្បៀងអាហារទាំងអស់មានការប្រែប្រួលបង្គួរប៉ុណ្ណោះ (≤៥%) ធៀបនឹងខែមុន លើកលែងតម្លៃត្រកួន ត្រីផ្ទក់ និងស៊ុតទា។ តម្លៃត្រកួនបានកើនឡើងគួរឱ្យកត់សម្គាល់គឺ ២៤,០% នៅជនបទ ហើយតម្លៃស៊ុតទាបានកើនឡើងគួរឱ្យកត់សម្គាល់នៅទីប្រជុំជនចំនួន ៧,៦% នៅជនបទ ធៀបនឹងខែមុន។ ខណៈតម្លៃត្រីផ្ទក់បានថយចុះ ៦,៩% នៅទីប្រជុំជនធៀបនឹងខែតុលា ឆ្នាំ២០២៣។

តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់ WFP មានការប្រែប្រួលតាមបណ្តាខេត្ត (ផែនទីខាងក្រោមស្តាំ) ដោយនៅផ្សារសាមគ្គី ក្នុងខេត្តកំពត (៣២,៨ ដុល្លារ) គឺខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ១៦% ខណៈនៅផ្សារស្វាង ក្នុងខេត្តត្បូងឃ្មុំ (២៤,២ ដុល្លារ) គឺទាបជាងតម្លៃមធ្យមថ្នាក់ជាតិ ១៥%។ តម្លៃកញ្ចប់ស្បៀងអាហារដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ពិសេសតម្លៃខ្ពស់ជាង ១០% ភាគច្រើនមាននៅផ្សារនៅទីប្រជុំជន។

**បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ**
ខែតុលា ឆ្នាំ២០២៣ និង ខែវិច្ឆិកា ឆ្នាំ២០២៣




*សម្គាល់៖*
*- ទិន្នន័យតម្លៃពីផ្សារចំនួន៥៦. មើលវិធីសាស្រ្តសម្រាប់ពត៌មានលម្អិត។*
*- តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

**តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ (ខែវិច្ឆិកា ឆ្នាំ២០២៣)**




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ទីប្រជុំជន |
|---|---|---|
| ≥ ១0% ខ្ពស់ជាង | 0% | ១00% |
| ៥% ទៅ ១0% ខ្ពស់ជាង | 0% | ១00% |
| < ៥% ខ្ពស់ជាង | ៥៥% | ៤៥% |
| < ៥% ទាបជាង | ៤៧% | ៥៣% |
| ៥% ទៅ ១0% ទាបជាង | ៥0% | ៥0% |
| ≥ ១0% ទាបជាង | ៧៥% | ២៥% |

# ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ

ប្រាក់ឈ្នួលពលកម្មសម្រាប់កម្មករក្នុងវិស័យកសិកម្ម និងសំណង់ត្រូវបានប្រមូលជារៀងរាល់ខែនៅទូទាំងប្រទេសដោយការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF)។ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ ប្រាក់ឈ្នួលពលកម្មមធ្យមថ្នាក់ជាតិ[1] សម្រាប់កម្មករគ្មានជំនាញបានកើនឡើងបង្គួរ ៣,៨% ធៀបនឹងខែមុន (MoM) និង ៦,៦% ធៀបនឹងខែដូចគ្នាកាលពីខែមុន (YoY) គឺមានតម្លៃ ៣៦.៨០០ រៀលក្នុងមួយថ្ងៃ ដែលមានតម្លៃប្រហែល ៩,០ ដុល្លារ។

កម្លាំងទិញស្បៀងអាហារ (ToT) ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្លាំងទិញស្បៀងអាហាររបស់គ្រួសារ ហើយត្រូវបានវាស់វែងដោយប្រើផលធៀបរវាងអត្រាប្រាក់ឈ្នួលកម្មករគ្មានជំនាញប្រចាំថ្ងៃ និងតម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋានប្រចាំថ្ងៃ[2]។ ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ ToT បានកើនឡើងបង្គួរ ៤,១% MoM និង ២,៥% YoY។ នេះបង្ហាញពីភាពប្រសើរឡើងនៃលទ្ធភាពទិញកញ្ចប់ស្បៀងអាហារមូលដ្ឋានរបស់កម្មករគ្មានជំនាញ។ ការកើនឡើងនេះដោយសារការថយចុះបន្តិចនៃតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងការកើនឡើងនៃប្រាក់ឈ្នួលពលកម្ម។

## ប្រាក់ឈ្នួលពលកម្ម (ខែវិច្ឆិកា ឆ្នាំ២០២៣)




## កម្លាំងទិញស្បៀងអាហារ (ខែវិច្ឆិកា ឆ្នាំ២០២៣)




*[1] នេះជាប្រាក់ឈ្នួលពលកម្ម ដែលមិនទាន់បានកែសម្រួលជាមួយអតិផរណា*

*[2] តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) ត្រូវបានគណនាជារៀងរាល់ខែដើម្បីបង្ហាញពីតម្លៃក្នុងមួយខែ។ ប៉ុន្តែ ដើម្បីគណនាកម្លាំងទិញស្បៀងអាហារ (ToT) តម្លៃក្នុងមួយខែនេះត្រូវបានបំលែងទៅជាតម្លៃក្នុងមួយថ្ងៃ ដើម្បីផ្តល់តម្លៃប៉ាន់ស្មានក្នុងមួយថ្ងៃ។*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ កម្ពុជាទទួលបានទឹកភ្លៀងជាមធ្យមសរុប* ខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ ក្នុងរយៈពេលដូចគ្នា បណ្ដាខេត្តភាគច្រើនទទួលបានទឹកភ្លៀងពីធម្មតា ទៅខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំបន្តិច (ផែនទីខាងក្រោមខាងស្ដាំ)។

ការព្យាករ El Niño, La Niña និង Southern Oscillation (ENSO) បានបង្ហាញថា បាតុភូតអែលនីញ៉ូរំពឹងថានឹងនៅតែមានឥទ្ធិពលខ្លាំង ហើយត្រូវបានព្យាករថានឹងបន្តរហូតដល់ខែឧសភា ឆ្នាំ២០២៤ ដែលធ្វើឱ្យមានស្ថានភាពកាន់តែក្ដៅ និងកាន់តែស្ងួត។ ផ្អែកតាមការព្យាករតាមរដូវកាលរបស់ International Research Institute (IRI) of Columbia University and European Centre for Medium-Range Weather Forecasts (ECMWF) ចន្លោះខែធ្នូ ឆ្នាំ២០២៣ ដល់ខែកុម្ភៈ ឆ្នាំ២០២៤ ខេត្តភាគច្រើននៃប្រទេសកម្ពុជាទំនងជាទទួលបានទឹកភ្លៀងទាបជាងធម្មតា និងមានធាតុអាកាសក្ដៅជាងធម្មតា។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (ខែវិច្ឆិកា ឆ្នាំ២០២៣) និងប្រតិទិនដាំដុះតាមរដូវកាល




| | | | | | |
|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | ប្រមូលផល | | | រៀបចំដី និង សាបព្រោះ |
| ស្រូវរដូវវស្សា | ប្រមូលផល | | រៀបចំដី និង សាបព្រោះ | ស្ទូង / ដាំដុះ | ប្រមូលផល |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

** កម្ពស់ទឹកភ្លៀងជាមធ្យមសរុបសម្រាប់ខែមួយគឺជាផលបូកនៃកម្ពស់ទឹកភ្លៀងក្នុងរយៈពេល ៣ដេកាត (រៀងរាល់១០ថ្ងៃ) ក្នុងខែនោះ។*

# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ រុក្ខជាតិ ដែលស្ថិតនៅតំបន់ដាំដុះដំណាំភាគច្រើននៃប្រទេសកម្ពុជា មានស្ថានភាពចន្លោះពីធម្មតាទៅប្រសើរជាងធម្មតា (ផែនទីខាងស្តាំ)។ ប៉ុន្តែ រុក្ខជាតិ ដែលស្ថិតនៅតំបន់ទំនាបពិសេសតំបន់ជុំវិញទន្លេសាប និងបឹងទន្លេសាប មានស្ថានភាពទាបជាងធម្មតា ដែលទំនងបណ្តាលមកជំនន់ទឹកភ្លៀងកាលពីដើមខែតុលា។

គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ ផ្ទៃដីប្រមូលផលស្រូវវស្សាសរុបសម្រេចបាន ១ លានហិកតា ជាមួយនឹងទិន្នផលប្រមាណ ៣,៧ តោន ក្នុងមួយហិកតា ដែលមានចំនួនប្រហាក់ប្រហែលនឹងឆ្នាំមុន។ ក្នុងរយៈពេលដូចគ្នា ផ្ទៃដីដាំដុះស្រូវប្រាំងសម្រេចបានប្រមាណ ២៣% នៃផែនការថ្នាក់ជាតិ។ ស្ថានភាពធាតុអាកាសអំណោយផលនាពេលបច្ចុប្បន្ន រួមនឹងទឹកស្រោចស្រពគ្រប់គ្រាន់ពីប្រព័ន្ធធារាសាស្ត្រ អំណោយផលដល់កាដាំដុះស្រូវរដូវប្រាំង (របាយការណ៍ទស្សនវិស័យកំណើនស្រូវក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ នៃប្រព័ន្ធព័ត៌មានសន្តិសុខស្បៀងអាស៊ាន)។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)**
**ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*

# ពាណិជ្ជកម្ម

ក្នុងរយៈពេលដប់មួយខែដំបូង ឆ្នាំ២០២៣ ការនាំចេញផ្លូវការសរុប (មិនរាប់បញ្ចូលមាសមិនមែនរូបិយវត្ថុ) របស់កម្ពុជាមានស្ថេរភាព ជាមួយនឹងការកើនឡើងបន្តិចគឺ ៣,១% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានតម្លៃ ២០.៤៩៤,៧ លានដុល្លារ។ ការនាំចេញទំនិញជាស្បៀងអាហារចំនួន ១.៩៨០ លានដុល្លារ (ក្រាហ្វិកខាងស្តាំ) ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ១.៥៨៣ លានដុល្លារ (+៥១% YoY ដោយសារការនាំចេញអង្ករបន្ថែមទៅកាន់ប្រទេសហ្វីលីពីន និងឥណ្ឌូនេស៊ី ក្នុងខែវិច្ឆិកា ឆ្នាំ២០២៣ ក៏ដូចជាការកើនឡើងតម្លៃអង្ករសកល) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុង ដែលអាចបរិភោគបាន បន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ៣៩៧ លានដុល្លារ (+៨% YoY)។ ក្នុងរយៈពេលដប់មួយខែដំបូងឆ្នាំ២០២៣ ការនាំចេញអង្ករមានចំនួនប្រមាណ ៦០០.០០០ តោន (មានតម្លៃស្មើ ៤២០,៨ លានដុល្លារ) សម្រេចបានជិត ៨៥% នៃគោលដៅនាំចេញប្រចាំឆ្នាំ (៧០០.០០០ តោន) ហើយការនាំចេញស្រូវមានចំនួន ៣,៩ លានតោន (មានតម្លៃស្មើនឹង ១.១៥៦,៧ លានដុល្លារ) ត្រូវបាននាំចេញក្នុងរយៈពេលដូចគ្នា (ដកស្រង់ដោយកាសែតប្រេសញូវ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣)។

ក្នុងរយៈពេលដប់មួយខែដំបូង ឆ្នាំ២០២៣ ការនាំចូលជាផ្លូវការសរុប (មិនរាប់បញ្ចូលមាសមិនមែនរូបិយវត្ថុ) របស់កម្ពុជាបានបានថយចុះ ៥,៤%% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន មានតម្លៃ ២២.០០៦ លានដុល្លារ។ មូលហេតុចម្បងនៃការថយចុះនេះ គឺដោយសារតែការថយចុះនៃការនាំចូលទំនិញមិនមែនស្បៀងអាហារពីប្រទេសផលិតសំខាន់ៗ ដូចជាប្រទេសតៃវ៉ាន់ សហរដ្ឋអាមេរិក ថៃ និងប្រទេសមួយចំនួនទៀត។ ការថយចុះនេះ អាចដោយសារតែការរំខានក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និងការផ្លាស់ប្តូរនៃតម្រូវការ បង្កឡើងដោយពហុវិបត្តិសកល ដូចជា ភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយ ផលប៉ះពាល់នៃបាតុភូតអែលនីញ៉ូ និងការរាតត្បាតជំងឺ។ វិបត្តិអស់ទាំងនេះបានធ្វើឱ្យមានការកើនឡើងនូវបញ្ហាបំណុល អតិផរណា និងបង្អាក់ដល់ការផលិត។

ក្នុងចំនោមការនាំចូលសរុប មានទំនិញជាស្បៀងអាហារចំនួន ១.១១៩ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ៧១ លានដុល្លារ (+៣៦% YoY) និងអាហារដទៃទៀតចំនួន ១.០៤៨ លានដុល្លារ (+៧% YoY)។ ក្នុងរយៈពេលដូចគ្នា ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ២៥០ លានដុល្លារ (+១៨% YoY) ភាគច្រើនមកពីប្រទេសវៀតណាម ថៃ និងចិន។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជា លានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ត្រឹម ខែវិច្ឆិកា ឆ្នាំ២០២៣




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ចូលថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០២៣*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០១៩ មក រដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមកម្មវិធីផ្ទេរសាច់ប្រាក់ដ៏ទូលំទូលាយមួយចំនួន ក្នុងគោលបំណងជួយដល់ស្ត្រីមានផ្ទៃពោះ និងកុមារអាហារក្រោម២ឆ្នាំ ក៏ដូចជាគ្រួសារក្រីក្រ និងងាយរងគ្រោះដែលរងផលប៉ះពាល់ដោយជំងឺរាតត្បាត ទឹកជំនន់ និងអតិផរណា។ កន្លងមក រដ្ឋាភិបាលកម្ពុជាបានចំណាយប្រាក់សរុប **១,៣ លានលានដុល្លារ** សម្រាប់កម្មវិធីទាំងអស់នេះ (ទំព័រហ្វេសប៊ុកផ្លូវការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣)។

កម្មវិធីជំនួយសាច់ប្រាក់សម្រាប់គ្រួសារមានប័ណ្ណសមធម៌ និងងាយរងគ្រោះ កំឡុងពេលការរាតត្បាតជំងឺកូវីដ-១៩ នឹងត្រូវបិទបញ្ចប់នៅក្នុងខែមីនា ឆ្នាំ២០២៤។ កម្មវិធីនេះនឹងបន្តជាមួយនឹង **"ក្របខណ្ឌកម្មវិធីជាតិជំនួយសង្គមថ្មីក្នុងកញ្ចប់គ្រួសារ** ដែលនឹងចាប់ផ្តើមចាប់ពីខែមេសា ឆ្នាំ២០២៤ តទៅ។ កញ្ចប់នេះពង្រីកវិសាលភាពគ្របដណ្តប់គ្រួសារមានប័ណ្ណសមធម៌ ដូចជាគ្រួសារដែលមានស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ អ្នកមានពិការភាព មនុស្សចាស់អាយុចាប់ពី៦០ឆ្នាំឡើងទៅ គ្រួសារដែលមានអ្នកផ្ទុកមេរោគអេដស៍ និងកម្មវិធីអាហារូបករណ៍សម្រាប់សិស្សក្រីក្រពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ (ដកស្រង់ដោយកាសែតហ្វ្រេសញូវ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៣) ជាមួយនឹងថវិកាបម្រុងសរុបចំនួន **១៦៥ លានដុល្លារ** សម្រាប់ឆ្នាំ២០២៤។

បេឡាជាតិរបបសន្តិសុខសង្គម (ប.ស.ស) នៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរៀបចំយុទ្ធនាការផ្សព្វផ្សាយពីផលប្រយោជន៍នៃសមាជិកភាព ប.ស.ស ជាមួយនឹងគម្រោងថែទាំសុខភាពថ្មីមួយ តាមរបបភាគទានដោយស្ម័គ្រចិត្ត។ គិតត្រឹមថ្ងៃទី១៩ ខែវិច្ឆិកា មានអ្នកចូលរួមសរុបចំនួន ១៩៧.៤០៨ ពិសេសបុគ្គលស្វ័យនិយោជន៍ (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣)។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយស្ថាប័នពាក់ព័ន្ធ កំពុងរៀបចំចេញជាផ្លូវការនូវសៀវភៅណែនាំដែលកំណត់ស្តង់ដារ វិធានការការពារកុមារ។ សៀវភៅណែនាំនេះនឹងរៀបរាប់អំពីនីតិវិធីប្រតិបត្តិការសម្រាប់អាជ្ញាធរក្នុងតំបន់ ក៏ដូចជាអង្គការសង្គមស៊ីវិល ដែលអាចឱ្យពួកគេផ្តល់សេវាប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពសម្រាប់កុមារ (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៣)។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

រដ្ឋាភិបាលបានត្រៀមខាតបង់ប្រហែល ១៣០ លានដុល្លារ ដើម្បីកាត់បន្ថយតម្លៃអគ្គិសនីនៅឆ្នាំនេះ ក្នុងគោលបំណងចម្បងជួយដល់វិស័យសេដ្ឋកិច្ចសំខាន់ៗ ដូចជា វិស័យកសិកម្ម ឧស្សាហកម្ម និងទេសចរណ៍ (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣)។

សហភាពអឺរ៉ុបបានផ្តល់ជំនួយ ចំនួន ៧ លានដុល្លារ ដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីធ្វើកំណែទម្រង់វិស័យជលផល រួមទាំងផ្តោតលើសុវត្ថិភាពចំណីអាហារ (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២៣)។




*ប្រភព៖ ទំព័រហ្វេសប៊ុកផ្លូវការរបស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម បិតផ្សាយនៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០២៣*

ចំនួនប្រជាជនបានចាក់វ៉ាក់សាំងកូវីដ-១៩




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្តើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្តាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្តុះបណ្តាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្តង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្តប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្តាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្តាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្តប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,709 | → -0.4% | ↑ 9.2% | ↑ 29.1% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 11,218 | ↓ -6.4% | ↓ -9.8% | ↑ 5.1% |
| ២.២ ត្រីប្រា(រស់) | Kg | 7,313 | → -2.0% | → -0.6% | → 0.3% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 7,796 | → -4.5% | → -2.7% | → -1.3% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 27,385 | → 0.0% | → -4.3% | ↑ 9.0% |
| ២.៥ ប្រហុក | Kg | 9,023 | → 0.7% | ↓ -6.4% | ↓ -11.9% |
| ៣.១ សាច់ជ្រូកពងជាន់ | Kg | 15,301 | → -1.1% | → -2.6% | ↓ -10.7% |
| ៣.២ សាច់គោឃារ | Kg | 17,170 | → 1.2% | → 3.5% | ↓ -12.2% |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 13,702 | ↓ -6.0% | ↓ -5.6% | → 3.9% |
| ៤.១ ស៊ុតទា | 10 eggs | 5,948 | → 2.9% | → 1.0% | ↓ -5.8% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 7,388 | → 2.0% | → 0.2% | → -2.1% |
| ៥.១ ប្រេងឆា | 5 litres | 26,440 | → -0.9% | → -0.4% | ↓ -16.7% |
| ៦.១ អំបិលម៉ត់អ៊ីយ៉ូត | Kg | 1,235 | → -2.6% | → 1.3% | → -2.9% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,476 | → 1.3% | → 1.5% | → 4.2% |
| ៧.១ សណ្តែកដី* | Kg | 10,138 | → 2.1% | → 1.7% | → 0.6% |
| ៧.២ សណ្តែកសៀង | Kg | 5,330 | → -4.0% | → -0.1% | ↑ 7.0% |
| ៧.៣ សណ្តែកខៀវ | Kg | 6,088 | → 1.8% | → 1.7% | → 4.1% |
| ៨.១ ត្រកួន | Kg | 3,554 | ↑ 8.9% | ↑ 25.9% | ↓ -6.8% |
| ៨.២ ការ៉ុត* | Kg | 3,069 | → -2.8% | ↓ -7.6% | ↓ -14.0% |
| ៨.៣ ស្លឹកបាស* | Kg | 5,115 | → 2.9% | ↑ 19.5% | ↓ -7.8% |
| ៨.៤ ស្លឹកម្រុំ* | Kg | 5,266 | → 1.2% | ↑ 6.0% | → 0.3% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 5,722 | ↑ 19.8% | ↑ 37.7% | ↑ 10.6% |
| ៨.៦ ម្ទេសតឿ* | Kg | 4,955 | ↑ 11.6% | ↑ 29.7% | ↑ 6.1% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 4,469 | ↑ 7.5% | ↑ 35.9% | ↑ 10.7% |
| ៨.៨ ម្ទេសខៀវ* | Kg | 4,267 | ↑ 7.0% | ↑ 17.5% | → 1.5% |
| ៨.៩ ផ្ទីដូង* | Kg | 4,797 | ↑ 14.1% | ↑ 22.9% | ↓ -11.2% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 5,525 | → 2.1% | ↑ 10.3% | ↓ -12.0% |
| ៨.១១ ត្រួយល្ពៅ* | Kg | 5,518 | ↑ 20.9% | ↑ 20.3% | → 2.6% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,410 | → 0.2% | → -0.2% | ↓ -18.5% |
| ៨.១៣ ឃ្លោក* | Kg | 2,633 | → 0.8% | ↑ 75.6% | ↓ -13.5% |
| ៨.១៤ ត្រឡាច | Kg | 2,457 | → -1.7% | ↓ -5.6% | ↓ -28.2% |
| ៨.១៥ ត្រប់វែង | Kg | 3,156 | ↑ 5.5% | → 2.5% | ↓ -22.8% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,513 | ↑ 12.8% | ↑ 28.9% | ↓ -16.5% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,697 | ↑ 15.5% | ↑ 25.3% | → 4.5% |
| ៨.១៨ ននោងមូល | Kg | 3,036 | ↑ 8.7% | → -0.2% | ↓ -17.0% |
| ៨.១៩ ននោងជ្រុង* | Kg | 3,305 | ↑ 16.2% | → -1.2% | ↓ -11.4% |
| ៨.២០ ល្ហុងខ្ចី* | Kg | 1,298 | → -3.0% | ↓ -22.1% | ↓ -15.7% |
| ៨.២១ សណ្តែកកួរ | Kg | 3,975 | → 3.5% | → -1.8% | ↓ -19.7% |
| ៨.២២ ត្រយូងចេក* | Kg | 2,116 | ↓ -12.6% | ↑ 7.4% | ↓ -9.6% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 7,783 | → -2.0% | → -0.8% | ↓ -6.7% |
| ៨.២៤ ដើមខាត់ណា* | Kg | 7,768 | ↑ 28.3% | ↑ 43.6% | ↑ 21.9% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,528 | → -1.3% | ↓ -10.1% | → 1.4% |
| ៨.២៦ ខ្ទឹមសរ | Kg | 7,181 | → 0.9% | ↓ -7.7% | ↑ 37.9% |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 4,025 | → 3.9% | → -1.7% | ↓ -9.1% |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,233 | → -1.4% | → -4.3% | → 4.9% |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 2,000 | ↑ 40.4% | ● | ↓ -11.1% |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 2,017 | ↓ -5.2% | → 2.0% | ↑ 17.2% |
| ១១.១ កូកាកូឡា | 330 ml | 1,946 | → -2.7% | → -2.7% | → 1.4% |
| ៧.១ សាំងធម្មតា | litre | 4,387 | → -2.4% | → -2.3% | → 0.8% |
| ៧.២ ម៉ាស៊ូត | litre | 4,403 | → -4.0% | → -0.7% | ↓ -11.9% |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,931 | → -1.0% | → 3.5% | ↓ -20.4% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,563 | → -0.2% | ↑ 10.3% | ↑ 32.6% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 10,141 | ↓ -5.9% | ↓ -10.4% | ↑ 5.5% |
| ២.២ ត្រីប្រា(រស់) | Kg | 6,544 | → -2.2% | → 2.4% | → 2.5% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 6,869 | ↓ -5.4% | → -3.8% | → -2.3% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 24,343 | → -4.1% | ↓ -8.5% | → 4.5% |
| ២.៥ ប្រហុក | Kg | 7,862 | → 0.1% | ↓ -7.5% | ↓ -13.6% |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 13,910 | → -2.2% | → -2.8% | ↓ -11.6% |
| ៣.២ សាច់គោឃាវ | Kg | 15,330 | → 0.5% | → 2.6% | ↓ -14.5% |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 12,417 | ↓ -7.7% | ↓ -7.4% | → 4.2% |
| ៤.១ ស៊ុតទា | 10 eggs | 5,529 | → 3.7% | → 2.1% | ↓ -5.7% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,801 | → 2.3% | → -1.5% | → -4.3% |
| ៥.១ ប្រេងឆា | 5 litres | 25,487 | → 0.2% | → 1.3% | ↓ -16.7% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 992 | → -0.9% | → 2.2% | → -2.0% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,111 | → 3.3% | → 3.7% | → 4.7% |
| ៧.១ សណ្តែកដី* | Kg | 9,227 | → 3.3% | → 2.3% | → 1.1% |
| ៧.២ សណ្តែកសៀង | Kg | 4,836 | → -1.5% | → 0.4% | → 3.6% |
| ៧.៣ សណ្តែកខៀវ | Kg | 5,573 | → 1.4% | → 1.6% | → 3.7% |
| ៨.១ ត្រកួន | Kg | 2,943 | ↑ 12.7% | ↑ 30.5% | ↓ -6.8% |
| ៨.២ ការ៉ុត* | Kg | 2,387 | → -2.0% | ↓ -11.9% | ↓ -18.0% |
| ៨.៣ ស្លឹកបាស* | Kg | 3,952 | ↑ 6.3% | ↑ 26.0% | ↓ -7.4% |
| ៨.៤ ស្លឹកម្រុំ* | Kg | 3,969 | → 4.2% | ↑ 9.9% | ↓ -10.0% |
| ៨.៥ ស្ពៃក្រញាញ់* | Kg | 4,903 | ↑ 22.3% | ↑ 41.3% | ↑ 11.2% |
| ៨.៦ ស្ពៃតឿ* | Kg | 4,081 | ↑ 11.5% | ↑ 32.6% | ↑ 5.8% |
| ៨.៧ ស្ពៃចង្កឹះ | Kg | 3,642 | → 5.0% | ↑ 40.5% | ↑ 11.5% |
| ៨.៨ ស្ពៃខៀវ* | Kg | 3,420 | ↑ 6.1% | ↑ 20.5% | → -0.9% |
| ៨.៩ ផ្ទីដូង* | Kg | 3,842 | ↑ 21.5% | ↑ 32.8% | ↓ -10.2% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 4,039 | → 1.2% | ↑ 12.6% | ↓ -14.7% |
| ៨.១១ ត្រយលល្ពៅ* | Kg | 4,223 | ↑ 24.3% | ↑ 20.3% | ↑ 6.4% |
| ៨.១២ ផ្លែល្ពៅ* | Kg | 1,888 | → 1.2% | ↑ 5.5% | ↓ -20.0% |
| ៨.១៣ ឃ្លោក* | Kg | 2,067 | → -2.8% | ↑ 37.8% | ↓ -12.5% |
| ៨.១៤ ត្រឡាច | Kg | 1,897 | → -1.5% | ↓ -5.8% | ↓ -32.8% |
| ៨.១៥ ត្រប់វែង | Kg | 2,520 | → 4.1% | → 4.8% | ↓ -27.2% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 2,933 | ↑ 23.3% | ↑ 40.3% | ↓ -16.8% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 4,005 | ↑ 18.7% | ↑ 31.7% | ↑ 5.7% |
| ៨.១៨ននោងមូល | Kg | 2,388 | ↑ 11.1% | → 4.6% | ↓ -21.4% |
| ៨.១៩ ននោងជ្រុង* | Kg | 2,555 | ↑ 19.7% | ↑ 5.0% | ↓ -16.7% |
| ៨.២០ ល្ពុងខ្ទឹ* | Kg | 953 | ↑ 5.1% | ↓ -18.9% | ↓ -15.7% |
| ៨.២១ សណ្តែកកួរ | Kg | 3,266 | → 4.2% | → -1.2% | ↓ -22.8% |
| ៨.២២ ត្រយូងចេក* | Kg | 1,647 | ↓ -13.2% | ↑ 13.2% | ↓ -11.3% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 6,787 | → -3.2% | → -1.1% | ↓ -6.5% |
| ៨.២៤ ដើមខាត់ណា* | Kg | 6,776 | ↑ 29.4% | ↑ 55.8% | ↑ 23.3% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,057 | → -0.4% | ↓ -8.3% | ↑ 8.4% |
| ៨.២៦ ខ្ទឹមសរ | Kg | 6,518 | → -0.2% | ↓ -8.5% | ↑ 43.9% |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 3,438 | → 3.7% | → -1.3% | ↓ -8.6% |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,776 | → -2.0% | ↓ -5.9% | ↑ 5.9% |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 1,500 | ↑ 46.3% | ● | ↓ -14.3% |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,760 | ↓ -7.8% | ↑ 5.7% | ↑ 13.7% |
| ១១.១ កូកាកូឡា | 330 ml | 1,535 | → -2.2% | → -1.5% | ↓ -5.4% |
| ៧.១ សាំងធម្មតា | litre | 4,143 | → -3.3% | → -2.1% | → -3.1% |
| ៧.២ ម៉ាស៊ូត | litre | 4,214 | → -3.5% | → -0.6% | ↓ -14.9% |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,486 | → 0.2% | ↑ 5.3% | ↓ -24.7% |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤
ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)
iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឱ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.7 | 34,032 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 11.2 | 31,061 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 15.3 | 18,944 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 9.5 | 3,429 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 5.8 | 2,268 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 3.6 | 25,051 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 2.5 | 1,508 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **116,300** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឱ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើយ។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*
*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៤ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*
*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*
*[4] បច្ចុប្បន្នភាពទីផ្សារ និងការតាមដានតាមរដូវកាល ខែវិច្ឆិកា ឆ្នាំ២០២៣ WFP ប្រចាំប្រទេសកម្ពុជា។*